# សេចក្តីជូនដំណឹង
# ស្តីពី
# ការបញ្ជាក់ជាថ្មីនូវចំណាត់ថ្នាក់ ឥណទានរបស់ធនាគារ ABA នៅកម្រិត ' B+' ជាមួយទស្សន វិស័យស្ថិរភាព ដោយភ្នាក់ងារវាយតម្លៃ Standard & Poor's Global

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ធនាគារ ABA) សូមប្រកាសថា នាថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២០នេះ ភ្នាក់ងារវាយតម្លៃ Standard & Poor's Global (S&P) បានបញ្ជាក់ជាថ្មីអំពីចំណាត់ថ្នាក់ឥណទានរបស់ធនាគារ ABA នៅកម្រិត 'B+' ជាមួយទស្សនវិស័យស្ថិរភាព។

ទស្សនវិស័យស្ថិរភាពឆ្លុះបញ្ចាំងពីទស្សនៈរបស់ S&P ដែលថា ធនាគារនឹងគ្រប់គ្រងប្រកបដោយចីរភាពនូវកំណើន យ៉ាងឆាប់រហ័សនៃប្រាក់កម្ចី និងប្រាក់បញ្ញើ ទោះបីជាមានការរីករាលដាលនៃវីរុសកូវីដ-19 ក៏ដោយ។ អ្នកជំនាញរបស់ S&P ក៏បានបញ្ចេញទស្សនៈថា និមិត្តសញ្ញាអាជីវកម្ម មូលធនកម្ម ប្រូហ្វាលហានិភ័យ និងថវិកា និងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ABA នឹងរក្សាមិនផ្លាស់ប្តូរដដែលក្នុងរយៈពេល ១២ ខែបន្ទាប់។

យោងតាមរបាយការណ៍របស់ S&P និមិត្តសញ្ញាអាជីវកម្មរបស់ធនាគារ ABA កំពុងតែមានភាពរឹងមាំ ដោយសារតែកំណើននៃចំណែកទីផ្សារដ៏គួរកត់សម្គាល់របស់ខ្លួន។ ធនាគារបន្តពង្រីកចំណែកទីផ្សារប្រាក់កម្ចី បណ្តាញចែកចាយរូបវន្ត និងឌីជីថល ព្រមទាំងមូលដ្ឋានអតិថិជនរបស់ខ្លួន។ S&P ជឿជាក់ថា មហិច្ឆតាក្នុងពង្រីកការគ្រប ដណ្តប់សេវា និងប្រសិទ្ធភាពប្រតិបត្តិការដ៏ល្អរបស់ធនាគារ ABA នឹងជួយគាំទ្រដល់ការទទួលបានប្រាក់ចំណេញលើសពីមធ្យម។

អ្នកជំនាញរបស់ S&P បានមានលើកឡើងជាពិសេសអំពីស្ថានភាពអាជីវកម្មដ៏មានស្ថិរភាព និងសក្តានុពលរបស់ធនាគារ ABA សម្រាប់កំណើនបន្ថែមទៀត ថា៖ " យើងរំពឹងថា ធនាគារ ABA នឹងបន្តទទួលបានកំណើនដ៏ខ្លាំងនិងលឿនពិតប្រាកដនៃនិមិត្តសញ្ញាអាជីវកម្ម និងផលបត្រកម្ចីរបស់ខ្លួន។ ធនាគារមានជំហររឹងមាំក្នុងការទទួលបានប្រាក់ចំណេញពីការងើបឡើងវិញ នៃសេដ្ឋកិច្ចដែលយើងរំពឹងថា នឹងកើតមានក្រោយបញ្ចប់ការរីករាលដាល នៃ វីរុសកូវីដ-១៩។ ជំហរនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកំណើនជាបន្តបន្ទាប់នៅក្នុងចំណែកទីផ្សារនៃប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ខ្លួន រយៈពេល ១៨ខែបន្ទាប់។"

ភ្នាក់ងារវាយតម្លៃអន្តរជាតិ S&P បានផ្តល់ចំណាត់ថ្នាក់ឥណទានកម្រិត 'B' ដល់ធនាគារ ABA នៅក្នុងឆ្នាំ ២០១៧។ ចំណាត់ថ្នាក់នេះត្រូវបានដំឡើងដល់កម្រិត 'B+' នៅឆ្នាំ ២០១៩ ផ្អែកលើកំណើននូវចំណែកទីផ្សារដែលកំពុងកើនឡើងដ៏សំខាន់នៃប្រាក់កម្ចី និងប្រាក់បញ្ញើ រួមនឹងការទទួលបានប្រាក់ចំណេញលើសពីមធ្យម។

ថ្ងៃអង្គារ ៨កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

**ធនាគារវឌ្ឍនៈអាស៊ី ចំកាត់**

ABA BANK
NATIONAL BANK OF CANADA GROUP

Head Office

No. 141, 146, 148 and 148 ABCD Preah Sihanouk Blvd,
and No. 15 and 153 ABC, Street 278, Sangkat Boeung Keng Kang 1,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia

Tel: (+855) 23 225 333
info@ababank.com
www.ababank.com

Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP